# សេចក្តីសង្ខេបអំពីដំណើរការ MVP 2.0

សម្រាប់ក្រុមការងារស្នូល MVP 2.0

2025 - 2026

Executive Office of Energy and Environmental Affairs

MVP
Municipal Vulnerability Preparedness

**ប្រើ MVP 2.0 ដើម្បី...**

# កសាងភាពធន់របស់សហគមន៍ចំពោះបម្រែបម្រួលអាកាសធាតុ

បណ្តាទីក្រុង និងទីប្រជុំជនទូទាំងរដ្ឋ Massachusetts កំពុងកំណត់ភាពងាយរងគ្រោះនៃអាកាសធាតុ ហើយកំពុងធ្វើការដើម្បីកសាងភាពធន់របស់សហគមន៍។ កម្មវិធី MVP 2.0 ពង្រីកការងារដែលបណ្តាសហគមន៍បានធ្វើរហូតមកដល់បច្ចុប្បន្ន និងគាំទ្រសហគមន៍ដោយប្រើ**វិធីសាស្ត្រ ឧបករណ៍ និងធនធានថ្មីៗ**សម្រាប់ការកសាងភាពធន់។

## តើអ្វីទៅជាភាពធន់របស់សហគមន៍?

ភាពធន់របស់សហគមន៍គឺជាសមត្ថភាពរបស់សហគមន៍ក្នុងការដោះស្រាយតម្រូវការរបស់ប្រជាជន អ្នកជិតខាង ប្រព័ន្ធអេកូឡូស៊ី និងហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីប្រមើលមើល ទប់ទល់ និងងើបឡើងវិញកាន់តែខ្លាំងពីគ្រោះថ្នាក់នៃបម្រែបម្រួលអាកាសធាតុ។

គ្រោះថ្នាក់រួមមានសីតុណ្ហភាពកាន់តែក្តៅ អាកាសធាតុអាក្រក់ខ្លាំង ការកើនឡើងកម្រិតកម្ពស់ទឹកសមុទ្រ ទឹកជំនន់ ភ្លៀងធ្លាក់កាន់តែខ្លាំង និងហេតុប៉ះពាល់ផ្សេងទៀត។

សហគមន៍ដែលធន់មិនគ្រាន់តែងើបឡើងវិញទេ — ថែមទាំងបន្តកាន់តែប្រសើរឡើងក្នុងការកាត់បន្ថយហេតុប៉ះពាល់នៃគ្រោះថ្នាក់អាកាសធាតុនាពេលអនាគត។

**កម្មវិធី MVP ដំណើរការដោយការិយាល័យប្រតិបត្តិកិច្ចការបរិស្ថាន (EEA) នៃរដ្ឋ Massachusetts។ សូមមើល [វេបសាយ MVP] សម្រាប់ព័ត៌មានលម្អិតបន្ថែម។**

# នៅក្នុងកម្មវិធី MVP 2.0 អ្នកនឹង៖

- កោះប្រជុំ **ក្រុមការងារស្នូល** ដើម្បីដឹកនាំដំណើរការ MVP 2.0 នៅក្នុងសហគមន៍របស់អ្នក
- ទទួលបាន**ការបង្វឹក**លើការកសាងភាពធន់នឹងអាកាសធាតុ សមធម៌ និងយុត្តិធម៌អាកាសធាតុ
- ពិនិត្យមើលឡើងវិញនូវអាទិភាពនៃភាពធន់របស់សហគមន៍អ្នកជាមួយនឹង**ការចូលរួមរបស់សហគមន៍កាន់តែទូលំទូលាយ**
- ធ្វើការរួមគ្នាដើម្បីអភិវឌ្ឍ និង**អនុវត្តគម្រោងពូជ** ដែលបង្កើតភាពធន់របស់សហគមន៍ ដោយមានការធានានូវមូលនិធិសម្រាប់ការអនុវត្តគម្រោង
- អនុវត្តដំណើរការដែលអាចធ្វើសាជាថ្មីសម្រាប់ **ការផ្តល់មូលនិធិជំនួយនាពេលអនាគត** (កម្មវិធី ប្រាក់ឧបត្ថម្ភសកម្មភាព MVP)

## តើអ្នកណានៅក្នុងក្រុមការងារស្នូល?

ក្រុមការងារស្នូលរបស់អ្នកនឹងត្រូវបានបង្កើតឡើងដោយមានសមាសភាព ប្រហែលដប់នាក់ រួមទាំងបុគ្គលិកសាលាក្រុង និងអ្នកទំនាក់ទំនងសហគមន៍។ អ្នកទំនាក់ទំនងសហគមន៍ គឺជាសមាជិកសហគមន៍ដែលមានទំនាក់ទំនងរឹងមាំ ជាមួយប្រជាជននៃយុត្តិធម៌បរិស្ថាន ឬប្រជាជនអាទិភាពផ្សេងទៀត។ សម្រាប់សហគមន៍តូចៗដែលមិនមានបុគ្គលិកសាលាក្រុងដែលមានប្រាក់ខែ "បុគ្គលិកសាលាក្រុង" អាចរួមបញ្ចូលសមាជិកសហគមន៍ដែលជារឿយៗដើរតួជាបុគ្គលិកសាលាក្រុង។

## តើគម្រោងពូជគឺជាអ្វី?

គម្រោងពូជគឺជាគម្រោងដែលត្រូវបានជ្រើសរើសដោយក្រុមការងារស្នូលដែលនឹងជំរុញអាទិភាពនៃភាពធន់របស់សហគមន៍ ហើយអាចបញ្ចប់ក្នុងរយៈពេល 9-10 ខែ។ សហគមន៍នឹងទទួលបាន $50,000 ដើម្បីបញ្ចប់គម្រោងពូជ។ (គម្រោងក្នុងតំបន់ទទួលបាន $50,000 ក្នុងមួយសហគមន៍។)

## ទស្សនទានស្នូល #1

# ប្រជាជននៃយុត្តិធម៌បរិស្ថាន

យុត្តិធម៌បរិស្ថានទទួលស្គាល់ថាក្រុមមនុស្សមួយចំនួនទទួលបានអត្ថប្រយោជន៍បរិស្ថានកាន់តែតិចជាងមុន ខណៈពេលដែលត្រូវបានប៉ះពាល់នឹងបរិស្ថានកាន់តែខ្លាំង ដោយសារតែការរើសអើងជាតិសាសន៍ វិសមភាពសេដ្ឋកិច្ច ឬភាពឯកោនៃភាសា។ នៅក្នុងរដ្ឋ Massachusetts ប្រជាជននៃយុត្តិធម៌បរិស្ថានគឺជាតំបន់ភូមិសាស្ត្រជាក់លាក់ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យមួយ ឬច្រើនដោយផ្អែកលើជាតិសាសន៍ ប្រាក់ចំណូល ឬភាសានិយាយ។

ចូលមើល **កម្មវិធីមើលផែនទី EJ** របស់ Massachusetts ដើម្បីមើលសង្កាត់ EJ នៅក្នុងសហគមន៍ តំបន់ ឬរដ្ឋរបស់អ្នក។

## ទស្សនទានស្នូល #2

# ប្រជាជនអាទិភាព

ប្រជាជនអាទិភាពគឺជាប្រជាជន ឬសហគមន៍ដែលអាចរងផលប៉ះពាល់វិសមាមាត្រដោយបម្រែបម្រួលអាកាសធាតុ ដោយសារស្ថានភាពជីវិតដែលបង្កើនការប្រឈមមុខនឹងគ្រោះថ្នាក់អាកាសធាតុ ឬធ្វើឱ្យកាន់តែពិបាកក្នុងការឆ្លើយតប។ បន្ថែមពីលើកត្តាដែលរួមចំណែកដល់ស្ថានភាពនៃយុត្តិធម៌បរិស្ថាន (ពោលៈ ប្រាក់ចំណូល ពូជសាសន៍ និងភាសា) កត្តាផ្សេងទៀតដូចជា សមត្ថភាពរាងកាយ លទ្ធភាពទទួលបានមធ្យោបាយធ្វើដំណើរ សុខភាព និងអាយុអាចបង្ហាញថាតើនរណាម្នាក់ ឬសហគមន៍របស់ពួកគេនឹងរងផលប៉ះពាល់វិសមាមាត្រដោយបម្រែបម្រួលអាកាសធាតុដែរឬអត់។ នេះត្រូវបានជំរុញដោយកត្តារួមចំណែកជាមូលដ្ឋាន ដូចជាការរើសអើងពូជសាសន៍ វិសមភាពសេដ្ឋកិច្ច ឬឧបសគ្គលទ្ធភាពប្រើប្រាស់ដែលបង្កើតភាពងាយរងគ្រោះ។

វាក្យសព្ទប្រជាជនអាទិភាពទទួលស្គាល់ថា តម្រូវការរបស់មនុស្សដែលមានបទពិសោធ និងជំនាញទាំងនេះត្រូវតែទទួលបានអាទិភាពនៅពេលបង្កើតដំណោះស្រាយនៃភាពធន់ដើម្បីកាត់បន្ថយភាពងាយរងគ្រោះចំពោះបម្រែបម្រួលអាកាសធាតុ។ **ទីក្រុងទាំងអស់មានប្រជាជនជាអាទិភាព ទោះបីជាពួកគេមិនមានសង្កាត់នៃយុត្តិធម៌បរិស្ថានដែលបានគូសផែនទីក៏ដោយ។**

**ទស្សនទានស្នូលកម្មវិធី MVP 2.0**

# ទិដ្ឋភាពទូទៅនៃដំណើរការ




## ដំណាក់កាលទី 1 (5 ខែ)

### បង្កើតក្រុមការងារស្នូល

(1) ការចាប់ផ្ដើមកសាងក្រុមរបស់អ្នក
(2) ការកំណត់ជំនាញរស់នៅ
(3) ការជ្រើសរើសបុគ្គលិកផ្សេងទៀតនៃក្រុមរបស់អ្នក

## ដំណាក់កាលទី 2 (6 ខែ)

### ពិនិត្យឡើងវិញនូវអាទិភាពនៃភាពធន់

(4) ការចាប់ផ្ដើមការសហការ
(5) ការស្វែងយល់ពីភាពធន់របស់សង្គម
(6) ការពិនិត្យមើលឡើងវិញនូវអាទិភាពនៃភាពធន់របស់សហគមន៍

## ដំណាក់កាលទី 3 (13 ខែ)

### អនុវត្តគម្រោងពូជ

(7) ការជ្រើសរើសគម្រោងពូជ
(8) ការបង្កើតផែនការអនុវត្ត
(9) ការអនុវត្តគម្រោងពូជ
(10) ការឆ្លុះបញ្ចាំង ការកែតម្រូវ និងជំហានបន្ទាប់

# តើអ្នកណាពាក់ព័ន្ធ?

ខាងក្រោមនេះគឺជាការចែករំលែកនូវតួនាទីផ្សេងៗ។ **តួនាទីនៅក្នុងប្រអប់ពណ៌ទឹកក្រូចគឺជាអ្នកដែលបង្កើតសមាសភាព ក្រុមការងារស្នូលរបស់អ្នក។** អ្នកផ្សេងទៀតគាំទ្រក្រុមការងារស្នូល។

**អ្នកគ្រប់គ្រងគម្រោងសាលាក្រុង** - នេះគឺជាបុគ្គលិកសាលាក្រុងដែលជួយដឹកនាំគម្រោង។ ពួកគេនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកជំនាញរៀបចំផែនការ និងដៃគូសមធម៌ ដើម្បីគាំទ្រដំណើរការ និងសម្របសម្រួលភស្តុភារកម្មពីភាគីសាលាក្រុង។

**សមាជិកក្រុមការងារស្នូលរបស់សាលាក្រុង** - ទាំងនេះគឺជាបុគ្គលិកសាលាក្រុងនៅក្នុងក្រុមការងារស្នូលរបស់អ្នក។ វាជាការល្អក្នុងការមានបុគ្គលិកដែលធ្វើអន្តរកម្មជាទៀងទាត់ជាមួយសហគមន៍។ សម្រាប់ក្រុងតូចៗ សមាជិកក្រុមទាំងនេះអាចជាបុគ្គលិកស្ម័គ្រចិត្តសាលាក្រុង។ បុគ្គលិកស្ម័គ្រចិត្តសាលាក្រុងអាចត្រូវបានផ្តល់សំណងតាមរយៈមូលនិធិជំនួយ។

**សមាជិកក្រុមការងារស្នូលនៃអ្នកទំនាក់ទំនងសហគមន៍** - អ្នកទំនាក់ទំនងសហគមន៍គឺជាសមាជិកក្រុមការងារស្នូលដែលមានទំនាក់ទំនងរឹងមាំជាមួយប្រជាជននៃយុត្តិធម៌បរិស្ថាន និងប្រជាជនអាទិភាពផ្សេងទៀតនៅក្នុងសហគមន៍ ឬតំបន់របស់អ្នក ហើយអ្នកដែលអាចជួយដឹកនាំ ឬសម្រួលដល់ការចុះផ្សព្វផ្សាយជាមួយសហគមន៍។ អ្នកទំនាក់ទំនងសហគមន៍ត្រូវបានផ្តល់សំណងសម្រាប់ពេលវេលារបស់ពួកគេតាមរយៈមូលនិធិជំនួយ។

**ដៃគូសមធម៌** - គ្រប់ទីក្រុង ឬតំបន់ក្នុងកម្មវិធី MVP 2.0 ត្រូវបានផ្គូផ្គងជាមួយដៃគូសមធម៌។ ដៃគូសមធម៌ជួយផ្តល់ការបង្វឹក និងការណែនាំអំពីអ្វីៗ ដូចជាការចូលរួមប្រកបដោយបរិយាបន្ន និងរបៀបវាស់ស្ទង់ហេតុប៉ះពាល់នៃគម្រោងលើសមធម៌។

**អ្នកជំនាញរៀបចំផែនការ** - គ្រប់ទីក្រុង ឬតំបន់នឹងជួលអ្នករៀបចំផែនការក្នុងជំហានទី 1។ អ្នកជំនាញរៀបចំផែនការនឹងជាអ្នកគ្រប់គ្រងគម្រោងសម្រាប់ជំហាន 2-8 (រហូតដល់ការអនុវត្តគម្រោងពូជ)។ អ្នកជំនាញរៀបចំផែនការនឹងជួយសម្រួលដល់ការពិភាក្សា សម្របសម្រួលភស្តុភារកម្ម និងត្រួតពិនិត្យការបញ្ចប់ការប្រគល់លទ្ធផល។

---

**ទីប្រឹក្សាប្រធានបទ** - ក្រុមការងារស្នូលអាចនាំទីប្រឹក្សាប្រធានបទសម្រាប់ជំហានទី 8 ដើម្បីជួយផ្តល់យោបល់លើផែនការអនុវត្តគម្រោងពូជរបស់ពួកគេ។ មានផ្នែកតូចមួយនៃមូលនិធិជំនួយដែលបានតម្កល់ទុកដើម្បីគាំទ្រទីប្រឹក្សាប្រធានបទ។

**អ្នកជំនាញអនុវត្ត** - អ្នកជំនាញអនុវត្តគឺជាបុគ្គល ឬក្រុមដែលសាលាក្រុងនឹងជួលឲ្យអនុវត្តគម្រោងពូជរបស់ពួកគេក្នុងជំហានទី 9 ។

---

**អ្នកសម្របសម្រួលប្រចាំតំបន់ MVP** - អ្នកសម្របសម្រួលប្រចាំតំបន់ MVP (RCs) គឺជាបុគ្គលិករដ្ឋដែលអាចឆ្លើយសំណួរ និងផ្តល់ការគាំទ្រគ្រប់ដំណាក់កាល។

## ទស្សនទានស្នូល #3

# ការផ្តោតលើសមធម៌

ដំណើរការ MVP 2.0 ផ្តោតលើសមធម៌ក្នុងការកសាងភាពធន់របស់សហគមន៍។ ការផ្តោតលើសមធម៌សំដៅលើការយកចិត្តទុកដាក់ជាពិសេស កាន់តែទូលំទូលាយ ទៅលើតម្រូវការរបស់មនុស្សដែលនឹងត្រូវបានរងផលប៉ះពាល់ខ្លាំងបំផុតដោយបម្រែបម្រួលអាកាសធាតុ និងធ្វើឱ្យប្រាកដថាលទ្ធផលទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ដល់សហគមន៍ទាំងនោះ។ ដើម្បីផ្តោតលើសមធម៌ ការសម្រេចចិត្តទាក់ទងនឹងអ្វីដែលចាំបាច់ក្នុងការកសាងភាពធន់ត្រូវតែត្រូវបានបង្កើតឡើងដោយជូនដំណឹងដោយ ឬដឹកនាំដោយមនុស្សដែលនឹងទទួលរងផលប៉ះពាល់ខ្លាំងបំផុតដោយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ។ សូមមើលទំព័រទី 4 ដើម្បីពិចារណាថាតើអ្នកណាអាចរងផលប៉ះពាល់ខ្លាំងបំផុតដោយបម្រែបម្រួលអាកាសធាតុនៅក្នុងសហគមន៍របស់អ្នក។

នៅពេលដែលយើងរៀបចំដំណោះស្រាយសម្រាប់ "សមាជិកសហគមន៍ទាំងអស់" ដោយមិនគិតពីរបៀបដែលដំណោះស្រាយនឹងទទួលបានអត្ថប្រយោជន៍ ឬកាត់បន្ថយគ្រោះថ្នាក់សម្រាប់មនុស្សដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយហេតុប៉ះពាល់អាកាសធាតុ ជារឿយៗ យើងបញ្ចប់ដោយពង្រឹងការដោះស្រាយបញ្ហាវិសមភាព និងភាពងាយរងគ្រោះនៅក្នុងសហគមន៍របស់យើង។ ការផ្តោតលើសមធម៌គឺចាំបាច់សម្រាប់ការបង្កើតសហគមន៍ដែលកាន់តែរឹងមាំ និងធន់ជាងមុន។

## ទស្សនទានស្នូល #4

# ជំនាញរស់នៅ

ជំនាញរស់នៅសំដៅលើបទពិសោធផ្ទាល់ ដែលអ្នកមិនទទួលបានតាមរយៈថ្នាក់រៀន ឬសៀវភៅសិក្សា។ វារួមបញ្ចូលចំណេះដឹង និងជំនាញលើបញ្ហា តម្រូវការ និងយុទ្ធសាស្ត្រសក្តានុពលសម្រាប់ដោះស្រាយបញ្ហាប្រឈមជាក់លាក់ដែលទទួលបានតាមរយៈបទពិសោធជីវិតប្រចាំថ្ងៃ — ថាតើវាមានបញ្ហាជាមួយនឹងអសន្តិសុខលំនៅឋាន អសន្តិសុខស្បៀង លទ្ធភាពទទួលបានការថែទាំសុខភាពមានកម្រិត ឧបសគ្គភាសា ឧបសគ្គដឹកជញ្ជូន ឬបទពិសោធជាមួយនឹងវិសមភាព ឬភាពមិនអាចចូលដំណើរការបានក្នុងរូបភាពផ្សេងៗដែរឬអត់។ ជំនាញរស់នៅរួមមានចំណេះដឹងប្រវត្តិសាស្ត្រ បទពិសោធផ្ទាល់ និងទស្សនៈពាក់ព័ន្ធ ដែលមានសារៈសំខាន់សម្រាប់ការជូនដំណឹងអំពីដំណោះស្រាយនៃភាពធន់របស់សហគមន៍។

# ដំណាក់កាលទី 1

# បង្កើតក្រុមការងារស្នូល

**ក្នុងដំណាក់កាលនេះ អ្នកនឹងបង្កើតក្រុមដែលនឹងធ្វើការរួមគ្នាដើម្បីពង្រឹងភាពធន់របស់សហគមន៍នៅក្នុងទីប្រជុំជន ទីក្រុង ឬតំបន់របស់អ្នក។**

**ដំណាក់កាលនេះត្រូវចំណាយពេលប្រហែល 5 ខែ** (ខែ 1-5 នៃដំណើរការ)។

## ជំហានទី 1 ការចាប់ផ្តើមកសាងក្រុមរបស់អ្នក

**ពេលវេលាកំណត់៖ 1-2 ខែ**

នៅក្នុងជំហានទី 1 អ្នកគ្រប់គ្រងគម្រោងសាលាក្រុងរបស់អ្នកជ្រើសរើសបុគ្គលិកសាលាក្រុងដើម្បីចូលរួមក្រុមការងារស្នូល។ ប្រសិនបើសហគមន៍របស់អ្នកតូចខ្លាំង ទាំងនេះអាចរួមបញ្ចូលបុគ្គលិកស្ម័គ្រចិត្តសាលាក្រុង (ដែលអាចទទួលបានប្រាក់ខែដើម្បីចូលរួមក្នុងគម្រោងនេះ)។ អ្នកគ្រប់គ្រងគម្រោងសាលាក្រុងរបស់អ្នកក៏ជួលអ្នកជំនាញរៀបចំផែនការ (អ្នកប្រឹក្សាយោបល់) ដើម្បីគាំទ្រដំណើរការនេះផងដែរ។

**ប្រសិនបើអ្នកជាសមាជិកក្រុមការងារស្នូលរបស់សាលាក្រុង នេះដល់ពេលដែលអ្នកនឹងចូលរួមក្នុងដំណើរការនេះហើយ!**

## ជំហានទី 2 ការកំណត់ជំនាញរស់នៅ

**ពេលវេលាកំណត់៖ 1 ខែ**

នៅក្នុងជំហានទី 2 សមាជិកក្រុមការងារស្នូលរបស់សាលាក្រុងសិក្សាទិន្នន័យសហគមន៍ ដើម្បីយល់កាន់តែច្បាស់ថាអ្នកណាដែលរស់នៅ និងធ្វើការនៅក្នុងសហគមន៍របស់ពួកគេ និងអ្នកណាដែលនឹងទទួលរងផលប៉ះពាល់ខ្លាំងបំផុតដោយបម្រែបម្រួលអាកាសធាតុ។ ជាផ្នែកនៃដំណើរការនេះ ពួកគេកំណត់ថាទស្សនៈរបស់អ្នកណានឹងមានសារៈសំខាន់ក្នុងការរួមបញ្ចូលនៅក្នុងក្រុមការងារស្នូលជាអ្នកទំនាក់ទំនងសហគមន៍។

## ជំហានទី 3 ការជ្រើសរើសបុគ្គលិកផ្សេងទៀតនៃក្រុមរបស់អ្នក

**ពេលវេលាកំណត់៖ 2 ខែ**

សមាជិកក្រុមការងារស្នូលរបស់សាលាក្រុងនឹងកំណត់ និងជ្រើសរើសអ្នកទំនាក់ទំនងសហគមន៍សម្រាប់ក្រុមការងារស្នូល។ វិធីសាស្រ្តមួយចំនួនអាចរួមបញ្ចូលការបង្ហោះការពិពណ៌នាការងារ ការទាក់ទងទៅអង្គការសហគមន៍មូលដ្ឋាន និងការនិយាយទៅកាន់មនុស្សនៅកន្លែងសាធារណៈដែលមនុស្សនៅក្នុងសហគមន៍របស់អ្នកប្រមូលផ្តុំ។ ដៃគូសមធម៌របស់ក្រុមអ្នកនឹងជួយក្រុមរបស់អ្នកឲ្យចូលរួម និងធ្វើឲ្យប្រាកដថា អ្នកគ្រប់គ្នាមានការគាំទ្រដែលពួកគេត្រូវការដើម្បីចូលរួមក្នុងដំណើរការនេះ។ មុននឹងបន្ត សូមចំណាយពេលដើម្បីធ្វើកម្មវិធីជួបនិងស្វាគមន៍ជាក្រុមពេញលេញ!

**ប្រសិនបើអ្នកជាសមាជិកក្រុមការងារស្នូលនៃអ្នកទំនាក់ទំនងសហគមន៍ នេះដល់ដែលអ្នកនឹងចូលរួមក្នុងដំណើរការនេះហើយ!**

# ដំណាក់កាលទី 2

# ពិនិត្យឡើងវិញនូវអាទិភាពនៃភាពធន់

**ក្នុងដំណាក់កាលនេះ អ្នកនឹងស៊ើបអង្កេតកត្តាដែលរួមចំណែកដល់ភាពងាយរងគ្រោះ ឬភាពធន់សម្រាប់មនុស្សនៅក្នុងសហគមន៍របស់អ្នក។ បន្ទាប់មកអ្នកនឹងប្រើប្រាស់លទ្ធផលរកឃើញរបស់អ្នកដើម្បីធ្វើបច្ចុប្បន្នភាពអាទិភាពនៃភាពធន់របស់សហគមន៍អ្នក។**

**ដំណាក់កាលនេះត្រូវចំណាយពេលប្រហែល 6 ខែ** (ខែ 6-11 នៃដំណើរការ)។

## ជំហានទី 4 ការចាប់ផ្តើមការសហការ

**ពេលវេលាកំណត់៖ 1 ខែ**

នៅក្នុងជំហានទី 4 ក្រុមការងារស្នូលធ្វើសកម្មភាពពីរបីនៃការកសាងក្រុម។ គោលដៅគឺដើម្បីស្វែងយល់បន្ថែមអំពីដំណើរការ MVP 2.0 ស្វែងយល់ពីគ្នាទៅវិញទៅមក និងដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ធ្វើការរួមគ្នាជាក្រុម។ សកម្មភាពទាំងនេះនឹងត្រូវបានសម្របសម្រួលដោយអ្នកជំនាញផែនការ និងដៃគូសមធម៌របស់អ្នក។

## ជំហានទី 5 ការស្វែងយល់ពីភាពធន់របស់សង្គម

**ពេលវេលាកំណត់៖ 3 ខែ**

ជាក្រុម បន្ទាប់មកអ្នកចាប់ផ្តើមស៊ើបអង្កេតកត្តាដែលរួមចំណែកដល់ភាពងាយរងគ្រោះ ឬភាពធន់សម្រាប់មនុស្សនៅក្នុងសហគមន៍របស់អ្នក។ អ្នកនឹងប្រើប្រាស់ “**ផែនទីបង្ហាញផ្លូវនៃភាពធន់របស់សង្គម**” ដែលសួរសំណួរណែនាំអំពីប្រធានបទដូចជា លំនៅឋាន ការដឹកជញ្ជូន និងអាហារ និងទឹកជាដើម។ អ្នកនឹងចាប់ផ្តើមបំពេញព័ត៌មានដោយប្រើទិន្នន័យសហគមន៍ និងអាកាសធាតុ និងចំណេះដឹងក្រុម។ បន្ទាប់មក អ្នកនឹងរៀបចំផែនការ និងអនុវត្តសកម្មភាពចុះផ្សព្វផ្សាយសហគមន៍ និងសកម្មភាពចូលរួមដើម្បីប្រមូលព័ត៌មានបន្ថែមពីសហគមន៍។ ដៃគូសមធម៌របស់អ្នកនឹងផ្តល់ការបង្វឹកអំពីរបៀបគិតអំពីសមធម៌អាកាសធាតុនៅក្នុងសហគមន៍របស់អ្នក និងការចូលរួមប្រកបដោយបរិយាបន្ន។

## ជំហានទី 6 ការពិនិត្យមើលឡើងវិញនូវអាទិភាពនៃភាពធន់

**ពេលវេលាកំណត់៖ 2 ខែ**

ទីប្រជុំជន ឬទីក្រុងរបស់អ្នកបានកំណត់អាទិភាពនៃភាពធន់របស់សហគមន៍ក្នុងអំឡុងពេលដំណើរការធ្វើផែនការ MVP 1.0 (ទំនងជា 5 ឆ្នាំមុន)។ គោលដៅរបស់អ្នកសម្រាប់ជំហានទី 6 គឺត្រូវពិនិត្យមើលឡើងវិញនូវអាទិភាពទាំងនោះ ហើយធ្វើបច្ចុប្បន្នភាពដោយផ្អែកលើព័ត៌មានថ្មីដែលអ្នកបានប្រមូលអំពីអ្វីដែលនឹងត្រូវការដើម្បីកសាងភាពធន់នៅក្នុងសហគមន៍របស់អ្នក។ បន្ទាប់មក អ្នកនឹងទាក់ទងទៅសហគមន៍ដើម្បីប្រមូលមតិកែលម្អលើអាទិភាពដែលបានធ្វើបច្ចុប្បន្នភាព ហើយកែសម្រួលវាប្រសិនបើចាំបាច់។

# ដំណាក់កាលទី 3

# អនុវត្ត គម្រោងពូជ

**ក្នុងដំណាក់កាលនេះ អ្នកនឹងកំណត់ អភិវឌ្ឍ និងអនុវត្តគម្រោងពូជដែលនឹងជំរុញអាទិភាពនៃភាពធន់របស់សហគមន៍អ្នក។**

**ដំណាក់កាលនេះត្រូវចំណាយពេលប្រហែល 13 ខែ** (ខែ 12-24 នៃដំណើរការ)។

## ជំហានទី 7 ការជ្រើសរើសគម្រោងពូជ

**ពេលវេលាកំណត់៖ 1 ខែ**

នៅក្នុងជំហានទី 7 ក្រុមការងារស្នូលកំណត់គំនិតគម្រោងពូជដ៏មានសក្ដានុពលពីមួយទៅដល់បីដែលអាចគាំទ្រដល់អាទិភាពនៃភាពធន់របស់ពួកគេ។ ពិនិត្យមើលសៀវភៅអំពីភាពធន់នឹងអាកាសធាតុនៅក្នុងទីក្រុង (និទាឃរដូវឆ្នាំ 2025) និងសកម្មភាពដែលត្រូវពិចារណា និងករណីសិក្សានៅក្នុងកម្មវិធី **GEAR** សម្រាប់ជាគំនិត។ បន្ទាប់មក អ្នកនឹងទាក់ទងទៅសហគមន៍ដើម្បីប្រមូលមតិកែលម្អលើគំនិតគម្រោងពូជដ៏មានសក្ដានុពល ហើយជ្រើសរើសមួយដើម្បីបន្តទៅមុខ។

---

## ជំហានទី 8 ការបង្កើតផែនការអនុវត្ត

**ពេលវេលាកំណត់៖ 1 ខែ**

ជាក្រុម បន្ទាប់មកអ្នកនឹងបង្កើតផែនការអនុវត្តសម្រាប់គម្រោងពូជរបស់អ្នក។ ដៃគូសមធម៌របស់អ្នកនឹងផ្តល់ការបង្ហឹកអំពីរបៀបវាស់ស្ទង់ហេតុប៉ះពាល់នៃគម្រោងលើសមធម៌។ មានមូលនិធិមួយចំណែកតូចដើម្បីជួល ទីប្រឹក្សាប្រធានបទឲ្យជួយផ្ដល់យោបល់លើការអភិវឌ្ឍគម្រោងរបស់អ្នក។ មុនពេលចាប់ផ្ដើមជំហានទី 9 អ្នកគ្រប់គ្រងគម្រោងសាលាក្រុងរបស់អ្នកនឹងដឹកនាំដំណើរការនៃការជួលអ្នកជំនាញ អនុវត្តដើម្បីអនុវត្តគម្រោងពូជ។

---

## ជំហានទី 9 ការអនុវត្តគម្រោងពូជ

**ពេលវេលាកំណត់៖ 10 ខែ**

នៅក្នុងជំហានទី 9 អ្នកនឹងអនុវត្តគម្រោងពូជរបស់អ្នក! ក្រុមការងារស្នូលនឹងធ្វើការជាមួយអ្នកជំនាញអនុវត្តដើម្បីអនុវត្តគម្រោងក្នុងរយៈពេលប្រហែល 9-10 ខែ។

---

## ជំហានទី 10 ការឆ្លុះបញ្ចាំង ការកែតម្រូវ ជំហានបន្ទាប់

**ពេលវេលាកំណត់៖ 1 ខែ**

ជាចុងក្រោយ អ្នកនឹងឆ្លុះបញ្ចាំងពីអ្វីដែលមានប្រសិទ្ធភាព និងអ្វីដែលអ្នកនឹងធ្វើខុសគ្នាសម្រាប់គម្រោងស្ដីពីភាពធន់នាពេលអនាគត! អបអរអ្វីទាំងអស់ដែលអ្នកបានសម្រេច ហើយពិចារណាអំពីគម្រោងផ្សេងទៀតដែលអ្នកអាចនឹងបន្តរកតាមរយៈការផ្តល់មូលនិធិ **ជំនួយដល់សកម្មភាព**។

**MVP 2.0**

resilient.mass.gov/mvp